# ព្រឹត្តិបត្រព័ត៌មាន

# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

ប.ស.ស ឆ្នាំទី០៥ លេខ១០ ឆ្នាំ២០១៥




ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម

## អ្នកមានជួយអ្នកក្រ
## អ្នកមានសុខភាពល្អជួយអ្នកឈឺ



## សេវាសង្គ្រោះបន្ទាន់ ២៤ ម៉ោង
## Hotline 1286

# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម.....១

២- បេឡាជាតិរបបសន្តិសុខសង្គមបានរៀបចំបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក.....២

៣- ដំណើរទស្សនកិច្ចសិក្សា ស្តីពីការគ្រប់គ្រងការផ្តល់សេវាបុននីតិសម្បទា នៅអង្គភាពសន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ .....៣

៤- ការចូលរួមសន្និសីទសន្តិសុខសង្គមអន្តរជាតិឆ្នាំ២០១៥ ស្តីពីសមាគមសន្តិសុខសង្គមអាស៊ាន (*International Social Security Conference 2015*) .....៤

៥- កិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់ការងារអាស៊ានលើកទី១១ នៅប្រទេសហ្វីលីពីន.....៥

៦- *ពិធីសំណេះសំណាលសួរសុខទុក្ខ និងប្រគល់សេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារជូនក្រុមគ្រួសារសពជនរងគ្រោះ នៅខេត្តត្បូងឃ្មុំ* .....៦

៧- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារ .....៧

៨- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះអង្កេតករណីកម្មករកម្មការិនីសន្លប់នៅរោងចក្រ C N Prosperrous Garment (Cambodia)Co.,ltd .....៨

៩- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះអង្កេតករណីកម្មករ-កម្មការិនីសន្លប់នៅរោងចក្រ South Land (Cambodia)Co.,Ltd .....៩

១០- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត .....១០

១១- ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារចុះបណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករដែលគ្មានបណ្ណបើកបរ នៅរោងចក្រ Cambo handsome Ltd .....១២

១២- កម្មករស្លាប់ និងរបួស ក្នុងហេតុការណ៍គ្រោះថ្នាក់បង្កដោយរថយន្តដឹកដីបុករថយន្តដឹកកម្មករ នៅតាមបណ្តោយផ្លូវជាតិលេខ៤ .....១៣

១៣- ករណីស្នើសុំការប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រ ..១៤

១៤- សេចក្តីជូនដំណឹង ស្តីពីនីតិវិធីនៃការបង់ភាគទាន .....១៥

១៥- សេចក្តីជូនដំណឹង .....១៦

១៦- សេចក្តីជូនដំណឹង ស្តីពីការអញ្ជើញសហគ្រាស គ្រឹះស្ថាន ខកខានមិនទាន់បានបង់ភាគទានហានិភ័យការងារមកបេឡាជាតិរបបសន្តិសុខសង្គម .....១៧

១៧- ទឹកជីវ៉ាន់ស៊ុយមានប្រសិទ្ធភាពសម្អាតជាតិពុលក្នុងតម្រងនោម .....១៨

១៨- ទស្សនអប់រំ .....១៩

១៩- ក្រុមប្រចាំការ HOTLINE 24 ម៉ោង.....២០

២០- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត .....២១

២១- លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស .....២២






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ម៉ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លេខានិពន្ធ លោកស្រី សុខ សូរ្យស្រី

កញ្ញា យ៉េម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# បេឡាជាតិរបបសន្តិសុខសង្គមបានរៀបចំបើកវគ្គ
# បណ្តុះបណ្តាលគ្រូបង្គោលអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

ដោយមើលឃើញពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ នៅតែកើតមានឡើងនៅតាមដងផ្លូវជាញឹកញាប់ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាលោកបានយកចិត្តទុកដាក់ពីបញ្ហាសុវត្ថិភាពចរាចរណ៍ក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ក៏ដូចជាបងប្អូនកម្មករនិយោជិតដែលធ្វើដំណើរទៅធ្វើការតាមរថយន្ត ឬម៉ូតូ និងធ្វើដំណើរដោយថ្មើជើង។ តាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានបង្ហាញឱ្យឃើញថាករណីគ្រោះ




ឯកឧត្តម សេង សក្កា អញ្ជើញជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពីច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក



ឯកឧត្តម សេង សក្កា អញ្ជើញថ្លែងសុន្ទរកថាបើក



ការធ្វើបទបង្ហាញរបស់លោក អ៊ុក សមវិទ្យា

ថ្នាក់កើតឡើងដោយសារអ្នកបើកបររថយន្តដឹកកម្មករមួយចំនួនមិនមានបណ្ណបើកបរត្រឹមត្រូវ, មិនគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងមិនបានចូលរៀននៅសាលាបានត្រឹមត្រូវ ហើយមិនយល់ពីវិធីត្រួតពិនិត្យបច្ចេកទេសយានយន្តមុនពេលបើកបរ។ ដើម្បីចូលរួមកាត់បន្ថយគ្រោះថ្នាក់ ដែលកើតមានចំពោះបងប្អូនកម្មករនិយោជិត។ បេឡាជាតិរបបសន្តិសុខសង្គម បានសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល អំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ជូនដល់បុគ្គលិកសហព័ន្ធ សហជីពចំនួន៩០ សហព័ន្ធសហជីព ស្មើនឹង១៨០នាក់ កាលពីព្រឹកថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ ក្រោមអធិបតីភាពឯកឧត្តម សេង សក្កា ប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ។ វគ្គបណ្តុះបណ្តាលនេះ ចែកចេញជាពីរវគ្គ ក្នុងមួយវគ្គមានសិក្ខាកាមចូលរួមចំនួន ៩០ នាក់ សិក្សារយៈពេលបីថ្ងៃ ដែលប្រារព្ធធ្វើឡើងនៅសាលប្រជុំបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ វគ្គនេះដែរធ្វើឡើងក្នុងទិសដៅដើម្បីឱ្យសហព័ន្ធ សហជីពមានសមត្ថភាពក្លាយជាជនបង្គោល មានលទ្ធភាពយកទៅផ្សព្វផ្សាយអប់រំបន្តដល់បុគ្គលិកសហជីព មូលដ្ឋានដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ របស់បងប្អូនកម្មករនិយោជិត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល៕



សិក្ខាកាមដែលជាតំណាង សហគ្រាស គ្រឹះស្ថាន សហជីព ចូលរួមក្នុងវគ្គបណ្តុះបណ្តាល

# ដំណើរទស្សនកិច្ចសិក្សា ស្តីពីការគ្រប់គ្រងការផ្តល់សេវាបុនធីតិសម្បទា នៅអង្គភាព សន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ



លោក អ៊ុក សមវិទ្យា និងសហការីអញ្ជើញទស្សនកិច្ចសិក្សា
នៅអង្គភាពសន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ

កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ លោក អ៊ុក សមវិទ្យា នាយក បេឡាជាតិរបបសន្តិសុខសង្គម ដឹកនាំសហការីរបស់ខ្លួនចំនួន ០៨រូប អញ្ជើញទៅធ្វើទស្សនកិច្ចសិក្សាចំនួន ០២ថ្ងៃ នៅអង្គភាពសន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ (SSO) ដើម្បីសិក្សា និងដកស្រង់បទពិសោធន៍ក្នុងការគ្រប់គ្រង ការផ្តល់សេវាបុននីតិសម្បទា សម្រាប់កម្មករនិយោជិត។ ការធ្វើទស្សនកិច្ចសិក្សានេះ ក្រុមការងារបានធ្វើទស្សនកិច្ចសិក្សាចំនួន ០២កន្លែង រួមមានអង្គភាពសន្តិសុខសង្គម (SSO) និងមជ្ឈមណ្ឌលផ្តល់សេវាបុននីតិសម្បទា (IRC) នៅខេត្តផាទុមថានី។

អង្គភាពសន្តិសុខសង្គម ជាអង្គភាពស្វយ័តដែលបានបង្កើតឡើងនៅឆ្នាំ១៩៩០ ស្ថិតនៅក្រោមអាណាព្យាបាលក្រសួងការងារ នៃព្រះរាជាណាចក្រថៃ។ ដែលគ្រប់គ្រងលើមូលនិធិចំនួន០២ រួមមានមូលនិធិសន្តិសុខសង្គម (Social Security Fund, SSF) និងមូលនិធិសំណងគ្រោះថ្នាក់ការងារ (Workmen Compensation Fund, WCF)។ ដែលមូលនិធិសន្តិសុខសង្គម ធានារ៉ាប់រងទៅលើយថាភាពមួយចំនួនដែលមិនមែនជាគ្រោះថ្នាក់ការងារ រួមមាន ជម្ងឺ, មាតុភាព, ពិការភាព, មរណៈភាព, វិភាជន៍សម្រាប់កុមារ, ជរាភាព និងនិកម្មភាព។ ចំពោះមូលនិធិសំណងគ្រោះថ្នាក់ការងារ ត្រូវបានបង្កើតនៅឆ្នាំ១៩៧៤ ធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ រួមមានគ្រោះថ្នាក់ពេលបំពេញការងារ ជម្ងឺវិជ្ជាជីវៈ និងការបាត់ខ្លួនរបស់កម្មករ។

មជ្ឈមណ្ឌលផ្តល់សេវាបុននីតិសម្បទាជាមជ្ឈមណ្ឌលសម្រាប់ផ្តល់សេវាបុននីតិសម្បទាដល់សមាជិករបស់ខ្លួន ដែលទទួលរងគ្រោះថ្នាក់នៅក្រោមមូលនិធិទាំង ០២។ មជ្ឈមណ្ឌលមានផ្តល់សេវាបុននីតិសម្បទាជាចម្បងចំនួន ០៣រួមមានផ្នែកវេជ្ជសាស្ត្រ, ផ្នែកវិជ្ជាជីវៈ, និងផ្នែកការងារសង្គម ព្រមទាំងសេវាគាំទ្រមួយចំនួនទៀត។ សេវាផ្សេងៗ ក្រៅពីសេវាចម្បងទាំង០៣ នេះ មជ្ឈមណ្ឌលក៏បានផ្តល់នូវសេវាមួយចំនួនទៀត ដោយឥតគិតថ្លៃផងដែររួមមានកន្លែងស្នាក់នៅ, អាហារ០៣ ពេល, ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងអនាម័យ, គម្រោងពង្រីកការអប់រំសម្រាប់យុវវ័យ, ការផ្តល់ព័ត៌មាន ពីការស្តារលទ្ធភាពពលកម្ម និងលើកកម្ពស់ សហគ្រិនសហគ្រាសធុនតូច និងសហគ្រិនវ័យក្មេង សម្រាប់អ្នកដែលមានបំណងប្រកបមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯង។



ការថតរូបអនុស្សាវរីយ៍ និងផ្លាស់ប្តូរវត្ថុអនុស្សាវរីយ៍



ការអញ្ជើញទស្សនកិច្ច ពីសកម្មភាពការងារ នៅអង្គភាពសន្តិសុខសង្គម

បន្ទាប់ពីការទស្សនកិច្ចសិក្សារយៈពេល ០២ ថ្ងៃនេះ បានទទួលនូវបទពិសោធន៍ និងមេរៀនល្អៗពីអង្គភាពសន្តិសុខសង្គម (SSO) និងមជ្ឈមណ្ឌលផ្តល់សេវាបុននីតិសម្បទា (IRC) បេឡាជាតិរបបសន្តិសុខសង្គម នឹងរៀបចំផែនការ នីតិវិធី និងបែបបទការងារ សម្រាប់ដាក់ឱ្យដំណើរការសេវាបុននីតិសម្បទា ឱ្យបានពេញលេញ ជូនកម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារឱ្យបាននៅឆ្នាំ២០១៥ នេះ៕

# ការចូលរួមសន្និសីទសន្តិសុខសង្គមអន្តរជាតិឆ្នាំ២០១៥ ស្តីពីសមាគមសន្តិសុខសង្គមអាស៊ាន (International Social Security Conference 2015)

កាលពីថ្ងៃទី១៩-២១ ខែឧសភា ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចាត់ លោក ស៊ុំ សោភ័ណ នាយករង ប.ស.ស និងមន្ត្រីមួយរូបទៅចូលរួមសន្និសីទសន្តិសុខសង្គមអន្តរជាតិឆ្នាំ២០១៥ ស្តីពីសមាគមសន្តិសុខសង្គមអាស៊ាន ដែលរៀបចំដោយអង្គភាព Employees Provident Fund (EPF) ប្រចាំប្រទេសម៉ាឡេស៊ី មានសិក្ខាកាមចូលរួមប្រហែល ៩៥០នាក់ មកពីបណ្តាប្រទេសអាស៊ាន និងស្ថាប័នពាក់ព័ន្ធ ដែលធ្វើឡើង នៅសណ្ឋាគារ Berjaya Times Square Hotel និងនៅ EPF Learning Centre ទីក្រុងកូឡាឡាំពួរ។

ទិសដៅនៃការចូលរួមសន្និសីទខាងលើនេះ គឺដើម្បីស្វែងយល់ពីមុខងារនៃការលើកឡើងអំពីទីផ្សារនៅក្នុងផលបត្រស្ថាប័ន ដើម្បីធានាទ្រទ្រង់ឱ្យបាននូវការវិនិយោគ សម្រាប់ប្រាក់ចំណូលពេលចូលនិវត្តន៍ ក៏ដូចជាការផ្លាស់ប្តូរចំណេះដឹងគ្នាទៅវិញទៅមកខាងវិស័យសន្តិសុខសង្គមឆ្នាំ២០១៥ នេះ។ ក្នុងសន្និសីទនេះបានលើកឡើងអំពីគោលដៅសំខាន់ៗ ដែលទាក់ទងទៅនឹងតម្រូវការផ្នែកសេវាសន្តិសុខសង្គម ដើម្បីអនុវត្តទៅតាមគោលនយោបាយសមាហរណកម្មអាស៊ាននាពេលខាងមុខ និងផ្តោតសំខាន់ទៅលើកំរិតជីវភាពរស់នៅរបស់មនុស្សចាស់ពេលចូលនិវត្តន៍៕



ការចូលរួមសន្និសីទសន្តិសុខសង្គមអន្តរជាតិ ស្តីពីសមាគមសន្តិសុខសង្គមអាស៊ាន


សិក្ខាកាមជាសមាជិកអាស៊ានចូលរួមសន្និសីទសន្តិសុខសង្គមអន្តរជាតិ



# កិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់ការងារអាស៊ានលើកទី១១ នៅប្រទេសហ្វីលីពីន

កាលពីថ្ងៃទី៦-៨ ខែឧសភា ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចាត់មន្ត្រីមួយរូបទៅចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់ការងារអាស៊ានលើកទី១១ និងកិច្ចប្រជុំពាក់ព័ន្ធដទៃទៀត (The 11th SLOM Meeting and Related Meeting) ដែលបានរៀបចំធ្វើឡើងដោយក្រសួងការងារ និងមុខរបរ នៃប្រទេសហ្វីលីពីន នៅសណ្ឋាគារសុហ្វីតែលហ្វីលីពីនផ្លាហ្សា, ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ព្រមទាំងមានសមាសភាពចូលរួមក្នុងកិច្ចប្រជុំមកពីបណ្តាប្រទេសអាស៊ាន និងអាស៊ានបូកបី និងសមាសភាពប្រតិភូកម្ពុជាមានចំនួន០៤រូប ដឹកនាំដោយ



សិក្ខាកាមចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់អាស៊ាន នៅប្រទេសហ្វីលីពីន



លោក ជួប ណារ៉ាត់ អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈ ដូចបានគ្រោងទុកដែលមានខ្លឹមសារដូចតទៅៈ អគ្គលេខាធិការដ្ឋានអាស៊ានបានលើកឡើងពីកិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់ការងារអាស៊ាន លើកទី១០ និងសេចក្តីសម្រេចនានា ដែលបានលើកឡើងក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការងារអាស៊ានលើកទី២៣ និងកិច្ចប្រជុំពាក់ព័ន្ធដើម្បី




ថ្នាក់ដឹកនាំក្រសួងការងារ និងមន្ត្រី ប.ស.ស ចូលរួមក្នុងកិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់

ធ្វើការតាមដាន និងអនុវត្តបន្ត។ បន្ថែមពីនេះលោកក៏បានសង្ខេបរបាយការណ៍ ស្តីពីលទ្ធផលសិក្ខាសាលាត្រួតពិនិត្យមើលឡើងវិញពាក់កណ្តាលអាណត្តិ និងពិភាក្សាបញ្ចប់លើសេចក្តីព្រាងលិខិតុបករណ៍អាស៊ាន ស្តីពីកិច្ចគាំពារសង្គម និងការផ្សព្វផ្សាយសិទ្ធិរបស់កម្មករទេសន្តរប្រវេសន៍។

កិច្ចប្រជុំផ្តោតសំខាន់ទៅលើ ០៥ចំណុចរួមមានៈ កិច្ចប្រជុំឧត្តមមន្ត្រីជាន់ខ្ពស់ការងារអាស៊ានលើកទី១១ (The 11th SLOM Meeting) ស្តីពីផែនការណ៍សកម្មភាព សម្រាប់ឆ្នាំ ២០១៦-២០២៣, កិច្ចប្រជុំពិភាក្សាបញ្ចប់លើសេចក្តីព្រាងលិខិតតូបករណ៍អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ACMW Meeting), កិច្ចប្រជុំឧត្តមមន្ត្រីការងារអាស៊ានបូកបី លើកទី១៣ (ចិន, ជប៉ុន និងសាធារណរដ្ឋកូរ៉េ SLOM+3), កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគម្រោងអាស៊ានជប៉ុន (PCC Meeting) និងកិច្ចប្រជុំ ស្តីពីការអភិវឌ្ឍធនធានមនុស្ស (HRD Meeting)។

បន្ទាប់មកលេខាធិការដ្ឋានបានស្នើឱ្យតំណាងស្ថាប័នដែលបានធ្វើសិក្ខាសាលាពីឆ្នាំ២០១៤ ដែលទទួលថវិកាពីគម្រោង ASEAN/Japan តាមរយៈក្រសួងសុខាភិបាលការងារ និងសុខមាលភាពសង្គមធ្វើការរាយការណ៍ និងថ្លែងអំណរគុណនាពេលនោះផងដែរ។

# ពិធីសំណេះសំណាលសួរសុខទុក្ខ និងប្រគល់សេចក្តីសម្រេចផ្តល់តាវកាលិក ហានិភ័យការងារជូនក្រុមគ្រួសារសពជនរងគ្រោះ នៅខេត្តត្បូងឃ្មុំ



លោក ម៉េង ហុង នាយករង ប.ស.ស អញ្ជើញជាអធិបតីក្នុងពិធី



បទបង្ហាញរបស់ លោក ម៉េង ហុង ក្នុងអង្គពិធី

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ លោក ម៉េង ហុង នាយករងបេឡាជាតិរបបសន្តិសុខសង្គម តំណាងលោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងសហការី បានចុះទៅសំណេះសំណាលសួរសុខទុក្ខ និងប្រគល់សេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ អត្ថប្រយោជន៍ សម្រាប់ផ្តល់ជូនក្រុមគ្រួសារជនរងគ្រោះ ដែលបានទទួលរងគ្រោះថ្នាក់ការងារ ចំនួន ៥,៣២៦,៦០០ រៀល ដល់គ្រួសារសពឈ្មោះ អ៊ុន សារ៉ន ភេទប្រុស អាយុ៥៦ ឆ្នាំ ដែលមានលំនៅដ្ឋានស្ថិតនៅឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ជាសន្តិសុខបម្រើការ នៅក្រុមហ៊ុន SOPHEAK NIKA INVESTMENT GROUP CO., LTD មានទីតាំងនៅឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលបានទទួលរងគ្រោះថ្នាក់ការងារ នៅពេលជនរងគ្រោះកំពុងដើរយាមប្រចាំការក្នុងក្រុមហ៊ុន ស្រាប់តែជំពប់ជើងដួលបោកក្បាលផ្នែកខាងក្រោយនឹងដុំថ្មបណ្តាលឱ្យរងរបួសធ្ងន់ បន្ទាប់មកជនរងគ្រោះ ក៏បានស្លាប់នៅមន្ទីរពេទ្យកាល់ម៉ែត។ អ្នកនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះមានតែ ប្រពន្ធ និងកូន។ ដូច្នេះ ប.ស.ស ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនដល់កូនត្រឹមអាយុ ១៨ឆ្នាំ។ ប្រសិនបើនៅសិក្សាផ្តល់រហូតដល់អាយុ ២១ឆ្នាំ។ ចំពោះប្រពន្ធ ឬប្តី ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែរហូតដល់រៀបអាពាហ៍ពិពាហ៍ថ្មី៕



សិក្ខាកាមដែលជាគ្រួសារជនរងគ្រោះចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់សេចក្តីសម្រេចតាវកាលិកហានិភ័យការងារ

# កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារ

ដើម្បីពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូន ដល់បងប្អូនកម្មករនិយោជិត ទើបនៅក្នុងខែឧសភា ឆ្នាំ២០១៥ កន្លងមកនេះ បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារ នៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន ចំនួន០៥ ក្នុងនោះនៅតាមបណ្តាខេត្ត០៣ និងរាជធានីភ្នំពេញ ចំនួន០២



បទបង្ហាញរបស់ លោក ជាវ ប៊ុនរិទ្ធ ក្នុងកិច្ចប្រជុំ

សហគ្រាស ដោយមានសមាសភាពចូលរួមពី មន្ត្រី និងបុគ្គលិកសាខា ប.ស.ស ខេត្ត ព្រមទាំងមានការចូលរួមពីលោក លោកស្រី ជានិយោជក នាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន ជាច្រើនរូបទៀត។

លោក **ម៉េង ហុង នាយករង ប.ស.ស** ក៏បានសបញ្ជាក់ពីគោលបំណង នៃកិច្ចប្រជុំនេះផ្តោតសំខាន់ទៅលើការពង្រឹងសេវារបស់មន្ទីរពេទ្យ សេវារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី សេវាសាខា ប.ស.ស ខេត្ត រួមទាំងបទបង្ហាញស្តីពីការចុះបញ្ជិកា ការប្រមូលភាគទាន ការចុះអធិការកិច្ច ការអង្កេតគ្រោះថ្នាក់ និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ជាធរមាន



សិក្ខាកាមដែលជានិយោជក និងតំណាងរោងចក្រ សហគ្រាសចូលរួមក្នុងកិច្ចប្រជុំ



បទបង្ហាញរបស់ លោក ម៉េង ហុង ក្នុងអង្គពិធី

ក្នុងន័យបង្កើនការយល់ដឹងក្នុងការអនុវត្ត និងសិទ្ធិក្នុងការទទួលបានតាវកាលិកដែលជាផ្នែកមួយដ៏សំខាន់ ដោយមានការចូលរួមពីគ្រប់ភាគីក្នុងការដោះស្រាយបញ្ហារួមគ្នាដើម្បីអភិវឌ្ឍន៍កិច្ចដំណើរការប្រព្រឹត្តទៅរបស់ ប.ស.ស ឱ្យកាន់តែល្អ និងមានប្រសិទ្ធិភាពខ្ពស់បន្ថែមទៀត។



ជាចុងបញ្ចប់នៃកិច្ចប្រជុំ លោក ម៉េង ហុង បានផ្តាំផ្ញើ ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន រាល់ពេលមានបញ្ហាផ្សេងៗទាក់ទងនឹងការផ្តល់សេវារបស់ ប.ស.ស អាចធ្វើការរាយការណ៍មកកាន់ស្នាក់ការកណ្តាល តាមរយៈលេខទូរស័ព្ទ ០២៣ ៨៨២ ៨៣៤, ០២៣ ៩៩៨ ៤១៧, ០២៣ ៩៩៨ ៤១៨ សម្រាប់ករណីសង្គ្រោះបន្ទាន់ទំនាក់ទំនងមកកាន់លេខ ១២៨៦ ដោយឥតគិតថ្លៃ។ លោកបានសំណូមពរឱ្យសហគ្រាស គ្រឹះស្ថាន ធ្វើការប្រកាសចំនួនកម្មករ និងការបង់ភាគទានឱ្យបានត្រឹមត្រូវ៕

# ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះអង្កេតករណីកម្មករ-កម្មការិនីសន្លប់នៅរោងចក្រ C N Prosperous Garment (Cambodia)Co.,ltd



កិច្ចប្រជុំពិភាក្សារបស់ក្រុមការងារ ដើម្បីរកមូលហេតុដែលបង្កឱ្យកម្មករសន្លប់

ដើម្បីបង្ការ និងទប់ស្កាត់កាត់បន្ថយករណីសន្លប់ ដែលកើតមានចំពោះបងប្អូនកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ដែលមានភារកិច្ចដូចខាងក្រោម៖ សិក្សាស្រាវជ្រាវ និងពិនិត្យរកមូលហេតុនៃការសន្លប់, ចាត់វិធានការសង្គ្រោះបន្ទាន់ និងទប់ស្កាត់ការសន្លប់របស់កម្មករនិយោជិតនៅកន្លែងធ្វើការ, សម្របសម្រួលសហការជាមួយមន្ទីរពេទ្យព្យាបាលដើម្បីបង្កើតរូបមន្តព្យាបាលសន្លប់ និងកំណត់តម្លៃព្យាបាល, សម្របសម្រួលសហការជាមួយស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដើម្បីដឹកជញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យព្យាបាលប្រកបដោយសុវត្ថិភាព និងទាន់ពេលវេលា ជាពិសេសធ្វើការរៀបចំណែនាំ ព្រមទាំងធ្វើការផ្សព្វផ្សាយអប់រំអំពីវិធីបង្ការគ្រោះថ្នាក់ការងារ, ដល់និយោជិតឱ្យយល់ដឹងនឹងអនុវត្តតាម។

ស្របគ្នានេះដែរ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោងប្រហែលជា ៨ និង០០ នាទីព្រឹក មានករណីកម្មការិនីសន្លប់ចំនួន ៦១នាក់ ស្រីចំនួន៥៨នាក់ នៅរោងចក្រ C N Prosperous Garment (Cambodia)Co.,ltd ដែលមាន ទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ០៣ ភូមិព្រៃកំបុត សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ហេតុការណ៍នេះ មន្ត្រី ប.ស.ស បានចុះទៅជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះដែលសន្លប់ទាំង ៦១នាក់ កំពុងសម្រាកព្យាបាលនៅបន្ទប់ពិគ្រោះ និងព្យាបាលជំងឺទូទៅ ប៉ាំងមុន្នីវុធ។ ចំពោះថ្លៃសេវាដឹកជញ្ជូន និងសេវាព្យា-



ការចុះសម្របសម្រួលរបស់មន្ត្រី ប.ស.ស នៅមន្ទីរពេទ្យ

បាលជនរងគ្រោះរហូតដល់ជាសះស្បើយ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ហេតុការណ៍កម្មករ-កម្មការិនីសន្លប់ខាងលើក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារនៃបេឡាជាតិរបបសន្តិសុខសង្គម ដឹកនាំដោយលោក ម៉េង ហុងនាយករងបេឡាជាតិរបបសន្តិសុខសង្គម និងសមាជិកក្រុមការងារបានចុះទៅត្រួតពិនិត្យ សិក្សារកពីមូលហេតុដែលបង្កឱ្យកម្មករនិយោជិតសន្លប់ និងចាត់វិធានការឱ្យនិយោជកធ្វើការកែលំអរចំណុចប្រឈមមួយចំនួន ព្រមទាំងណែនាំបន្ថែមពីបញ្ហាសុខភាពដល់កម្មករនិយោជិតផងដែរ៕



# ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះអង្កេតករណីកម្មករកម្មការិនីសន្លប់នៅរោងចក្រ South Land (Cambodia)Co.,Ltd

ដើម្បីបង្ការ និងកាត់បន្ថយករណីសន្លប់ ដែលកើតមានចំពោះកម្មករនិយោជិត ដូចនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត និងតាមបណ្តាសហគ្រាសគ្រឹះស្ថាន ដែលមានភារកិច្ចដូចខាងក្រោម៖ សិក្សាស្រាវជ្រាវ និងពិនិត្យរកមូលហេតុសន្លប់, ចាត់វិធានការសង្គ្រោះបន្ទាន់ និងទប់ស្កាត់ការសន្លប់របស់កម្មករនិយោជិតនៅកន្លែងធ្វើការ, សម្របសម្រួលសហការជាមួយមន្ទីរ ពេទ្យព្យាបាល ដើម្បីបង្កើតរូបមន្តព្យាបាលសន្លប់ និងកំណត់ពីតម្លៃព្យាបាល, សម្របសម្រួលសហការជាមួយស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីដឹកជញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យព្យាបាលប្រកបដោយ



ការចុះសាកសួរ និងពិនិត្យផ្ទាល់នៅកន្លែងកើតហេតុ

សុវត្ថិភាព និងទាន់ពេលវេលា ជាពិសេសធ្វើការរៀបចំណែនាំ និងផ្សព្វផ្សាយកម្មវិធីបង្ការគ្រោះថ្នាក់ការងារ, ដល់និយោជកឱ្យយល់ដឹង និងអនុវត្តតាម។

ស្របជាមួយគ្នានេះដែរ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោងប្រហែលជា ៨ និង៣០ នាទីព្រឹក មានករណីកម្មការិនីសន្លប់ចំនួន ១៩នាក់ នៅរោងចក្រ South Land (Cambodia) Co.,Ltd ដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង សង្កាត់ចោមចៅ ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ហេតុការណ៍នេះ មន្ត្រី ប.ស.ស បានចុះទៅជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះទាំង ១៩នាក់ ទៅព្យាបាលនៅមន្ទីរព្យាបាលមូលមិត្តចំនួន១៤នាក់ ០៤នាក់ទៀត សម្រាកព្យាបាលនៅពេទ្យសម្តេចអង្គ និង ០១នាក់ទៀត សម្រាកព្យាបាលនៅមន្ទីរពេទ្យឯកជនខាងមុខរោងចក្រ។

ចំពោះថ្លៃសេវាដឹកជញ្ជូន និងសេវាព្យាបាលជនរងគ្រោះរហូតដល់ជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

ក្នុងហេតុការណ៍កម្មករ-កម្មការិនីសន្លប់ខាងលើក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ នៃបេឡាជាតិរបបសន្តិសុខសង្គម ដឹកនាំដោយឯកឧត្តមវេជ្ជ. ប៉ុក វណ្ណថាត ជាប្រធានក្រុមការងារ ទ.ស.ប.ក និងសមាជិកក្រុមការងារ បានចុះទៅត្រួតពិនិត្យសិក្សារកមូលហេតុ ដែលបង្កឱ្យកម្មករនិយោជិតសន្លប់ និងចាត់វិធានការឱ្យនិយោជក ធ្វើការកែលំអរចំណុចប្រឈមមួយចំនួន ព្រមទាំងណែនាំដល់និយោជក ឬតំណាងអំពីការងារ លក្ខខណ្ឌអនាម័យ និងលក្ខខណ្ឌផ្សេងទៀត ដើម្បីណែនាំបន្តដល់កម្មករនិយោជិតឱ្យអនុវត្តបានល្អ និងខ្ជាប់ខ្ជួនផងដែរ។



រូបភាពជនរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ



# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត



ការឡើងមានចំណាប់អារម្មណ៍របស់តំណាងនិយោជកក្នុងអង្គពិធី

ដោយមើលឃើញអំពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ កើតមានជារៀងរាល់ថ្ងៃភាគច្រើន ផ្តើមចេញពីអ្នកបើកបរមិនបានគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដោយមានការធ្វេសប្រហែស ការបើកបរលើសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងជាដើម។ តាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ករណីគ្រោះថ្នាក់មួយចំនួនទៀតកើតឡើងដោយសារអ្នកបើកបររថយន្តដឹកកម្មករ មិនមានបណ្ណបើកបរត្រឹមត្រូវ, មិនគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ជាពិសេសមិនបានចូលរៀននៅសាលាបានត្រឹមត្រូវហើយមិនយល់ពីវិធីត្រួតពិនិត្យបច្ចេកទេសយានយន្តមុនពេលបើកបរ។

ដើម្បីចូលរួមក្នុងការកាត់បន្ថយនូវគ្រោះថ្នាក់ទាំងនេះ ទើបនៅក្នុងខែឧសភា ឆ្នាំ២០១៥ កន្លងមកនេះក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិ អ្នកបើកបរដឹកកម្មករនិយោជិតឱ្យបានយល់ដឹង និងគោរពច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកឱ្យមានប្រសិទ្ធភាព។ នៅក្នុងខែឧសភា កន្លងមកនេះក្រុមការងារ បានចុះធ្វើការ ផ្សព្វផ្សាយអប់រំតាមបណ្តាសហគ្រាស គ្រឹះស្ថាន នៅតាមបណ្តារាជធានី/ខេត្ត ចំនួន០៤ រួមមាន៖ សហគ្រាស LONG LEAD (CAMBODIA) CO.,LTD ខេត្តកំពង់ឆ្នាំង, នៅសាលាស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង, សហគ្រាស SKY HIGH (CAMBODIA) CO.,LTD នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ, និងនៅសហគ្រាស SHEICO (PHNOM PENH) CO.,LTD នៅខណ្ឌដង្កោ រាជធានីភ្នំពេញ, ដោយមានការអញ្ជើញចូលរួមជាអធិបតី ពីថ្នាក់ដឹកនាំបេឡាជាតិរបបសន្តិសុខសង្គម ក៏ដូចតាមបណ្តាក្រសួងជំនាញពាក់ព័ន្ធដែលមានសមាសភាពក្នុងក្រុមការងារមន្ត្រីប៉ូលីសជំនាញសណ្តាប់ធ្នាប់ចរាចរណ៍ខេត្ត និយោជក ឬតំណាង និងមានសមាសភាពចូលរួមពីអ្នកបើកបរដឹកកម្មករនិយោជិតជាច្រើននាក់ទៀត។



សិក្ខាកាមដែលជាអ្នកបើកបរចូលរួមក្នុងអង្គពិធី



លោក ជាវ ប៊ុនរិទ្ធ ឡើងធ្វើបទបង្ហាញក្នុងកិច្ចប្រជុំ

ជាកិច្ចបន្ទាប់គ្រូឧទ្ទេសនាម បានធ្វើបទបង្ហាញស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ផ្លាកសញ្ញាគំនូសបំព្រួញ សុជីវធម៌ក្នុងការបើកបរ ទោសប្បញ្ញត្តិផ្សេងៗ បច្ចេកទេសត្រួតពិនិត្យ និងថែទាំយានយន្ត និងវិជ្ជាសង្គ្រោះបឋម មុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ និង



ទិដ្ឋភាពសិក្ខាកាមរៀនពាក់មួកសុវត្ថិភាពឱ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

ចំណុចសុវត្ថិភាពចរាចរណ៍ផ្សេងៗទៀតដូចជា ពាក់មួកសុវត្ថិភាព និងខ្សែក្រវ៉ាត់សុវត្ថិភាពឱ្យបានត្រឹមត្រូវ បំរាមនៃការសេពគ្រឿងស្រវឹងក្នុងពេលបើកបរ បើកបរមិនឱ្យហួសល្បឿនកំណត់ ការជែង ឬវ៉ាគ្នា ការមិនឱ្យធ្វើដំណើរតាមយានយន្តដែលផ្ទុកលើសចំណុះ ការចេះអធ្យាស្រ័យគ្នា ការគោរពសិទ្ធិអាទិភាព ការមិនឱ្យប្រើទូរស័ព្ទដៃក្នុងពេលបើកបរ ការតម្រូវឱ្យមានប័ណ្ណបើកបរត្រឹមត្រូវ ការមិនឱ្យមានចំណាំងផ្លាតលើខ្លួន ឬយានយន្តក្នុងពេលធ្វើដំណើរពេលយប់ ឬកន្លែងគ្មានពន្លឺជាដើម។

ឆ្លៀតឱកាសនោះដែរ សមាជិកក្រុមការងារ ក៏បានលើកឡើងពីគោលបំណង នៃកិច្ចប្រជុំផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិអ្នកបើកបរយានយន្ត ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនូវចំនួនអ្នកបើកបរដឹកកម្មករនិយោជិត។ ដើម្បីឱ្យស្របតាមផែនការសកម្មភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដើម្បីចូលរួមផ្សព្វផ្សាយអប់រំទប់ស្កាត់កាត់បន្ថយគ្រោះថ្នាក់ការងារ ដែលផ្តោតសំខាន់លើ គ្រោះថ្នាក់ពេលធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការផងដែរ៕



ការណែនាំរបស់ប៉ូលីសជំនាញអំពីរបៀបពាក់មួកសុវត្ថិភាពឱ្យត្រឹមត្រូវតាមបច្ចេកទេស

# ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារចុះបណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករដែលគ្មានបណ្ណបើកបរ នៅរោងចក្រ CAMBO HANDSOME LTD

ដើម្បីរួមចំណែកកាត់បន្ថយករណីគ្រោះថ្នាក់ ដែលកើតមានចំពោះបងប្អូនកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម បានចាត់ឱ្យក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ បានរៀបចំវគ្គបណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិតនៅរោងចក្រ CAMBO HANDSOME LTD ដែលមានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



លោកស្រី បុប្ផា ផានី ធ្វើបទបង្ហាញក្នុងអង្គពិធី

កិច្ចប្រជុំដឹកនាំដោយលោកស្រី បុប្ផា ផានី សមាជិកក្រុមការងារ ស.ផ.ក និងជាអនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ និងជាសមាជិកក្រុមការងារ ស.ផ.ក ព្រមទាំងមានការចូលរួមពីអ្នកបើកបរដឹកកម្មករនិយោជិតជាច្រើនអ្នកទៀត។

គោលបំណងវគ្គបណ្តុះបណ្តាលនេះ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដល់បងប្អូនកម្មករនិយោជិត ដែលមិនមានថវិកា និងពេលវេលាគ្រប់គ្រាន់ក្នុងការទៅសិក្សានៅសាលាបង្រៀនបើកបរមានចំងាយឆ្ងាយ និងត្រូវចំណាយថវិកាច្រើន។

ដោយពិនិត្យឃើញនូវកត្តាទាំងនេះ ទើបបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន




ការធ្វើតេស្តិ៍ជៃចង្កូតផ្ទាល់របស់សិក្ខាកាមម្នាក់ៗ



បទបង្ហាញរបស់ លោក ជាវ ប៊ុនរិទ្ធ ក្នុងកិច្ចប្រជុំ

បើកវគ្គបណ្តុះបណ្តាលនេះឡើង ដើម្បីឱ្យបងប្អូនកម្មករអាចទទួលបណ្ណបើកបរស្របច្បាប់។ ក្នុងឱកាសនោះដែរ លោក ជាវ ប៊ុនរិទ្ធ បានជម្រាបជូនដល់បងប្អូនអ្នកបើកបរដឹកកម្មករនិយោជិតឱ្យខិតខំរៀនសូត្រ ស្តាប់គ្រូពន្យល់ ដើម្បីត្រៀមខ្លួនក្នុងការ ប្រឡងយកបណ្ណបើកបរនាពេលខាងមុខ។

ជាកិច្ចបន្ត លោកស្រី បុប្ផា ផានី សមាជិកក្រុមការងារ ស.ផ.ក និងជាគ្រូបង្រៀនផ្នែកទ្រឹស្តីក្នុងវគ្គបណ្តុះបណ្តាល ប្រឡង និងផ្តល់



សិក្ខាកាមដែលជាអ្នកបើកបរចូលរួមក្នុងអង្គពិធី

បណ្ណបើកបរ បានធ្វើបទបង្ហាញនូវចំណុចធំៗមួយចំនួនដូចជាៈ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបង្ហាញពីសញ្ញាចរាចរណ៍ដែលមានសញ្ញារបស់ភ្នាក់ងារចរាចរណ៍, ភ្លើងសញ្ញាចរាចរណ៍, ផ្លាកសញ្ញាចរាចរណ៍, សញ្ញាសិទ្ធិអាទិភាព, គំនូសសញ្ញាចរាចរណ៍, សិទ្ធិអាទិភាពលើផ្លូវប្រសព្វ ព្រមទាំងជំនាញបើកបររថយន្តធុនតូច, បច្ចេកទេសរថយន្តធុនតូច។

ចុងក្រោយក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានធ្វើការផ្តាំផ្ញើដល់បងប្អូនកម្មករ និងអ្នកបើកបរដឹកកម្មករនិយោជិត ដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរណ៍ ក្នុងពេលធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ពីផ្ទះទៅកន្លែងធ្វើការ និងពីកន្លែងធ្វើការត្រឡប់មកផ្ទះ៕

# កម្មករស្លាប់ និងរបួស ក្នុងហេតុការណ៍គ្រោះថ្នាក់បង្កដោយរថយន្តដឹកដីបុក រថយន្តដឹកកម្មករ នៅតាមបណ្តោយផ្លូវជាតិលេខ៤

ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយនៅតាមបណ្តោយផ្លូវជាតិលេខ៤ ស្ថិតនៅក្បែរវត្តកំបូល កាលពីវេលាម៉ោង ១៨ និង៣០ នាទីល្ងាច ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។ ហេតុការណ៍គ្រោះថ្នាក់នេះបង្កដោយរថយន្តដឹកដីបុកជាមួយរថយន្តដឹកកម្មកររោងចក្រ New Ever Green មានទីតាំងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសបណ្តាលឱ្យកម្មករ-កម្មការិនី ១នាក់ បានស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ និង៦នាក់ផ្សេងទៀតរងរបួសធ្ងន់។

ករណីគ្រោះថ្នាក់ខាងលើបានកើតឡើងខណៈពេលដែលកម្មករកម្មការិនីចេញពីកន្លែងធ្វើការត្រឡប់មកផ្ទះ តាមរយៈរថយន្តដឹកកម្មករ លុះមកដល់ចំណុចកើតហេតុស្រាប់តែមានរថយន្តដឹកដីមួយគ្រឿងមកបុករថយន្តដឹកកម្មករតែម្តង។ ក្រោយពីទទួលបានដំណឹង សាខា ប.ស.ស ខណ្ឌ និងថ្នាក់កណ្តាលបានចុះទៅដល់កន្លែងកើតហេតុភ្លាមៗ និងបានបញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។

ដោយជនរងគ្រោះដែលស្លាប់ និងរងរបួសក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ខាងលើជាសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ដូចនេះ ប.ស.ស បានធ្វើការសម្របសម្រួល និងផ្តល់គោលរបបសន្តិសុខសង្គម ជូនដល់ជនរងគ្រោះ និងអ្នកនៅក្នុងបន្ទុកផ្ទាល់រួមមាន៖ ជនរងគ្រោះដែលស្លាប់ ប.ស.ស ផ្តល់ជូនថ្លៃដឹកសពទៅស្រុកកំណើត, ផ្តល់ប្រាក់សោហ៊ុយបូជាសពចំនួន៤លានរៀល, ផ្តល់គោលរបបឧបត្ថម្ភ កូន ប្រពន្ធ ឬប្តី និងជនចាស់ជរាដែលនៅក្នុងបន្ទុកផ្ទាល់។ ចំពោះជនរងគ្រោះ ដែលរងរបួសធ្ងន់ និងស្រាលត្រូវទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ដូចជា៖ ថ្លៃបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ, ថ្លៃសង្គ្រោះបន្ទាន់, ថ្លៃព្យាបាលរហូតដល់ជាសះស្បើយ, ប្រាក់បំណាច់ប្រចាំថ្ងៃពេលសម្រាកព្យាបាល, និងផ្តល់ឧបករណ៍រណបដៃ ជើងអវៈយវៈសិប្បនិម្មិត, លើសពីនេះនឹងផ្តល់ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈឡើងវិញស្របតាមកាយសម្បទា៕



រូបភាពជនរងគ្រោះ ក្រោយពេលទទួលគ្រោះថ្នាក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ: ៤៥៦៥ សក

ភ្នំពេញ ថ្ងៃទី ១៥ ខែ ៥ ឆ្នាំ ២០១៥

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ ៖** ករណីស្នើសុំការប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំអ្នកបើកបរ។

**យោង ៖** លិខិតលេខ ២១៦២ ក.ប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបើកបរដឹកជញ្ជូនកម្មករនិយោជិតនៅតាមរោងចក្រអាចទទួលបណ្ណបើកបរបានស្របតាមច្បាប់កំណត់ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមឯកភាពតាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំ ដោយអនុវត្តតាមនីតិវិធីនៃការបណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរ ដែលមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់ដឹកកម្មករនិយោជិត(ស.ដ.ក) ក្នុងការអនុវត្តផ្ទាល់នៅតាមមូលដ្ឋានរោងចក្រដែលមានការប្រមូលផ្តុំអ្នកបើកបរច្រើន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប តាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អាន ពីខ្ញុំ។

**ចម្លងជូន ៖**
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
  «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

មហាវិថីព្រះនរោត្តម, ភ្នំពេញ    ទូរស័ព្ទ-ទូរសារ (៨៥៥) ២៣ ៨៤ ៣៥ ៧៤ (៨៥៥) ២៣ ៨៤ ២៥ ៦៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ១០/១៥ ប.ស.ស

# សេចក្តីជូនដំណឹង

# ស្តីពីនីតិវិធីនៃការបង់ភាគទាន

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានជ្រាបថា ដើម្បីសម្រួលដល់ដំណើរការនៃការបង់ភាគទាន ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម ៖

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

១- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ

២- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈសេវាកម្មអ៊ីនធើណេតបែងឃីង (Internet Banking) ឬ សេវាកម្មយូនីធី (Unity) ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ តទៅ ។ រាល់ការចំណាយសេវាកម្មនេះជាបន្ទុកផ្ទាល់របស់និយោជក ។

៣- ចំពោះបង្កាន់ដៃបង់ភាគទាន របាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬ ឯកសារពាក់ព័ន្ធនានា និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យ ប.ស.ស ឬ ផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

*សម្គាល់ ៖*

ចំពោះលោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានរួចហើយ ផ្ញើរបាយការណ៍កម្មករនិយោជិតតាមរយៈសារអេឡិចត្រូនិច ត្រូវមានឯកសារដូចជា ៖

- របាយការណ៍កម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច E-Form)
- លិខិតប្រកាសបង់ភាគទានហានិភ័យការងារ
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- តារាងបើកប្រាក់បៀវត្សកម្មករ និយោជិត (ទម្រង់អេឡិចត្រូនិច Payroll)

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ [illegible] ឆ្នាំ២០១៤

អាគារលេខ [illegible] មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: [illegible]
ទូរសារ : [illegible] , ប្រអប់សំបុត្រ P.O.Box [illegible]
Website : www.nssf.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ០០១/១៥ ប.ស.ស

# សេចក្តីជូនដំណឹង

